

# ការរួមចំណែករបស់ខ្ញុំ

### ចំណាប់អារម្មណ៍ ព្រះតេជគុណ ច័ន្ទ ធឿង

" អាត្មាបានចូលរួម ក្នុងការជួយគាំទ្រដល់អ្នកផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ និងមនុស្ស ដែលងាយរងគ្រោះដោយសារមេរោគអេដស៍/ជំងឺអេដស៍ ព្រោះអាត្មាយល់ថា ការជួយសង្គ្រោះ ដល់ពួកគេដើម្បីទទួលបាននូវក្ដីសង្ឃឹមឡើងវិញ គឺមានសារៈសំខាន់ណាស់។ ការជួយនេះអាច ធ្វើអោយសង្គមរបស់យើងឈានទៅរកភាពរុងរឿង និងស្របតាមពុទ្ធឱវាទរបស់ព្រះពុទ្ធអង្គ" ។

### ចំណាប់អារម្មណ៍ លោក ឆាយ វិចស៊ី អភិបាលរងស្រុកជើងព្រៃ

" ខ្ញុំយល់ថាការចូលរួមជួយគាំទ្ររបស់ខ្ញុំក្នុងការជួយលើកទឹកចិត្ត និងលើកស្ទួយជីវភាពរបស់ អ្នកផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ឱ្យមានភាពប្រសើរឡើង និងលើកកំពស់ជីវិតប្រកបដោយ សេចក្ដីថ្លៃថ្នូរ។ តាមរយៈការចុះអប់រំផ្សព្វផ្សាយតាមមូលដ្ឋាន និងចុះទៅសួរសុខទុក្ខដោយផ្ទាល់ ដល់អ្នកផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ គឺជាប្រការដ៏សំខាន់ក្នុងការចូលរួមកាត់បន្ថយការរីក រាលដាលនៃមេរោគអេដស៍/ជំងឺអេដស៍នៅក្នុងប្រទេស។"


### សេចក្ដីថ្លែងអំណរគុណ

ក្រុមការងារផលិតសំភារៈអប់រំផ្សព្វផ្សាយនៃបណ្ដាញអ្នកផ្ទុកមេរោគអេដស៍ប្រចាំព្រះរាជាណាចក្រកម្ពុជា សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ព្រះសង្ឃ លោកអភិបាលរងស្រុក អង្គការណាស់ សមាជិកក្រុមគាំទ្រក្រុម អ្នកផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ និងលោក លោកស្រី ដែលបានចំណាយពេលដ៏មានតំលៃក្នុងការផ្ដល់នូវព័ត៌មាន និងអនុញ្ញាតិឱ្យក្រុមការងារយើងខ្ញុំ ចុះថត និងបញ្ចូលរូបភាពជាក់ស្ដែងនៅក្នុងកូនសៀវភៅនេះ ។ យើងខ្ញុំក៏សូមថ្លែងអំណរគុណ ផងដែរចំពោះក្រុមហ៊ុនផលិតឱសថហ្វាយសឺ និងអង្គការផេកកម្ពុជា ដែលបានផ្ដល់នូវជំនួយ បច្ចេកទេស និងថវិកាក្នុងការផលិតកូនសៀវភៅនេះឡើងសំរាប់ធ្វើការអប់រំផ្សព្វផ្សាយនៅក្នុង ប្រទេសកម្ពុជា។

**ផលិតដោយ**

ភ្នំពេញ

តុលា ២០០៥

បណ្ដាញនៃអ្នកផ្ទុកមេរោគអេដស៍
និងជំងឺអេដស៍ប្រចាំព្រះរាជាណាចក្រកម្ពុជា

អាត្មាព្រះនាម **ច័ន្ទ យឿង**
គង់នៅវត្ត **ប្រាសាទនាងខ្មៅ**
ខេត្តតាកែវ ។
អាត្មាយល់ថាអេដស៍ជាបញ្ហា
របស់យើងទាំងអស់គ្នា ។





ហេតុនេះព្រះសង្ឃមានតួនាទី សំខាន់ណាស់ក្នុងការចូលរួមទប់ស្កាត់
ការរីករាលដាលនៃមេរោគអេដស៍/ជំងឺអេដស៍ និងជួយដល់អ្នក
ដែលបានទទួលរងគ្រោះដោយសារមេរោគអេដស៍/ជំងឺអេដស៍ ។



អាត្មាបានប្រមូលបច្ច័យ និងចង្ហាន់
ពីសប្បុរសជន និងញាតិញោម
ក្នុងភូមិ ដើម្បីជួយដល់អ្នកផ្ទុក
មេរោគអេដស៍/ជំងឺអេដស៍
និងកូនចៅរបស់គេ ។







អាត្មាចុះសួរសុខទុក្ខ និង ជួយសាងសង់ផ្ទះដល់គ្រួសារអ្នកផ្ទុកមេរោគ
អេដស៍/ជំងឺអេដស៍ដែលក្រីក្រ ។



អាត្មាបានអប់រំពិក្ខុសង្ឃពីការ
ជួយគាំទ្រដល់អ្នកផ្ទុកមេរោគ
អេដស៍/អ្នកជំងឺអេដស៍

បានបង្រៀនកុមារកំព្រា
និងកុមារដែលរងគ្រោះ
ដោយសារ មេរោគ
អេដស៍/ជំងឺអេដស៍ពីអក្សរ
សាស្ត្រខ្មែរ និងលេខនពន្ធ



ខ្ញុំបាទឈ្មោះ ឆាយ វ៉ាន់ស៊ី ជាអភិបាលរងស្រុកជើងព្រៃ ខ្ញុំយល់ថាការចូលរួម ជួយដល់អ្នករងគ្រោះដោយសារមេរោគអេដស៍/ជំងឺអេដស៍គឺសំខាន់ណាស់ ព្រោះថា ពួកគេគឺជាអ្នកដែលទទួលរងគ្រោះដោយសារមេរោគអេដស៍/ជំងឺអេដស៍ ។



ខ្ញុំចូលរួមអប់រំផ្សព្វផ្សាយ និងលើកកំពស់ សិទ្ធិអ្នកផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ ។







ខ្ញុំផ្តល់ហិបសង្គ្រោះដល់វត្ត ឈូក ដើម្បីប្រមូលបច្ច័យជួយដល់អ្នកផ្ទុកមេរោគ អេដស៍/ជំងឺអេដស៍ និងកុមារដែលរងគ្រោះដោយសារមេរោគអេដស៍/ជំងឺអេដស៍





ខ្ញុំបានចូលរួមប្រជុំចែករំលែកបទពិសោធន៍ជាមួយក្រុមគាំទ្រក្រុម និងចុះសំណេះសំណាលជាមួយគ្រួសារអ្នកផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ ដើម្បីលើកទឹកចិត្តពួកគេឱ្យចេះតស៊ូក្នុងជីវិត ។







ខ្ញុំជានាថាមណ្ឌលសុខភាពយើងខ្ញុំ តែងតែទទួល និងផ្ដល់សេវាសុខភាពដល់អ្នកផ្ទុកមេរោគអេដស៍/ជំងឺអេដស៍យ៉ាងយកចិត្តទុកដាក់ ។



ខ្ញុំឈ្មោះ ឡោ ចន្ថា ជាអ្នកលក់ដូរម្នាក់ហើយខ្ញុំធ្លាប់បានជួយធ្វើការអប់រំ
និងគាំទ្រដល់អ្នកផ្ទុកមេរោគអេដស៍/ជំងឺអេដស៍



ដូចជា: ជួយអប់រំយុវជនឱ្យចេះបង្ការខ្លួនពីការឆ្លងមេរោគអេដស៍ ។



ចែករំលែកម្ហូបអាហារជាមួយអ្នកផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ ។





ខ្ញុំបានជួលផ្ទះខ្ញុំឱ្យអ្នកផ្ទុកមេរោគអេដស៍/អ្នកជំងឺអេដស៍ស្នាក់នៅ




ខ្ញុំបានជួយបញ្ជូនអ្នកផ្ទុកមេរោគអេដស៍/អ្នកជំងឺអេដស៍ទៅមណ្ឌលសុខភាព ព្រោះខ្ញុំ
យល់ឃើញថា អ្នកផ្ទុកមេរោគអេដស៍/អ្នកជំងឺអេដស៍ក៏ជាមនុស្សដូចយើងដែរ ។

ខ្ញុំបាទឈ្មោះ សួង សុខហៃ ជានិស្សិតម្នាក់បានឆ្លៀតពេលពីការសិក្សា ជួយធ្វើការអប់រំផ្សព្វផ្សាយអំពីមេរោគអេដស៍/ជំងឺអេដស៍ និងជួយគាំទ្រ អ្នកផ្ទុកមេរោគអេដស៍/អ្នកជំងឺអេដស៍ ។



សួរសុខទុក្ខផ្ទុកអ្នកមេរោគអេដស៍/អ្នកជំងឺអេដស៍ ។








ខ្ញុំបានបរិច្ចាគថវិកាផ្ទាល់ខ្លួនដើម្បីជួយដល់អ្នកផ្ទុកមេរោគអេដស៍/អ្នកជំងឺអេដស៍ ។



ខ្ញុំសប្បាយចិត្តណាស់នៅពេលដែលបានចូលរួមចំណែកក្នុងសកម្មភាពសង្គម ជាមួយអ្នកផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ ។

ក្នុងនាមជាអ្នកផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ម្នាក់ ខ្ញុំរំភើបចិត្តណាស់នៅពេលដែល
ប្រជាជននៅក្នុងសហគមន៍ជួយឧបត្ថម្ភ និងគាំទ្រដល់រូបនាងខ្ញុំនិងគ្រួសារ ។



យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការជួយឧបត្ថម្ភ និងគាំទ្រទាំង
ផ្នែកសំភារៈ និងស្មារតី ដល់អ្នកផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ដូចជាយើងខ្ញុំ ។



សូមជូនពរ ដល់លោក-អ្នកដែលជាសប្បុរសជនទាំងអស់ បានប្រកបតែនឹង
សេចក្តីសុខគ្រប់ប្រការ ។





អាត្មាបានអំពាវនាវដល់បងប្អូន
ប្រជាពលរដ្ឋយើងឱ្យចូលរួមចំណែក
ក្នុងការ ទប់ស្កាត់ការរីករាលដាលនៃ
មេរោគអេដស៍/ជំងឺអេដស៍ និងជួយ
ឧបត្ថម្ភគាំទ្រ ដល់អ្នកផ្ទុកមេរោគ
អេដស៍/ជំងឺអេដស៍នៅក្នុងសហគមន៍ ។



យើងខ្ញុំក៏សូមឱ្យលោក-អ្នកជួយគាំទ្រដល់អ្នកផ្ទុកមេរោគអេដស៍/ជំងឺអេដស៍នៅ
ក្នុងសហគមន៍របស់លោក-អ្នកផងដែរ ព្រោះថានៅពេលដែលយើងជួយគ្នាទៅវិញ
ទៅមក នោះយើងនឹងអាចធ្វើឱ្យជីវិតយើងគ្រប់គ្នាមានភាពកាន់តែប្រសើរឡើង ។

# សកម្មភាពចូលរួមគាំទ្ររបស់អ្នកសហគមន៍ដល់ អ្នកផ្ទុកមេរោគអេដស៍/ជំងឺអេដស៍





សហការជាមួយ
គណៈកម្មាធិការផ្តល់ប្រឹក្សាលើសំភារៈអប់រំ និងផ្សព្វផ្សាយ

**ជំនួយបច្ចេកទេស និង ឧបត្ថម្ភដោយ**

BUILDING CAPACITY WORLDWIDE
Pact Cambodia

Pfizer Foundation

**ព័ត៌មានបន្ថែមសូមទំនាក់ទំនង :**

-បណ្តាញនៃអ្នកផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍ប្រចាំព្រះរាជាណាចក្រកម្ពុជា (CPN+)
ផ្ទះលេខ ៧១ ផ្លូវលេខ ៣៦៨ សង្កាត់ទួលស្វាយព្រៃ ១ ខ័ណ្ឌចំការមន ក្រុងភ្នំពេញ
ទូរស័ព្ទលេខ : ០២៣ ២១៦ ៣៩៩, ០១១ ៨១៦ ៦៧១, ០១២ ៩៥៤ ៨៨៨
អ៊ីមែល : cpn@online.org.kh

-អង្គការផេកកម្ពុជា (Pact Cambodia)
មជ្ឈមណ្ឌលភ្នំពេញ ជាន់ទី ៣
កែងផ្លូវព្រះសីហនុ (២៧៤) និងមហាវិថីព្រះសុធារស
សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ
ទូរស័ព្ទ/ទូរសារ : (៨៥៥-២៣) ២១៧ ៨៥៥ , ២១៧ ៨៥៦
អ៊ីមែល : pact@pactcambodia.org វេបសាយ : www.pactcambodia.org

បោះពុម្ពផ្សាយលើកទី ១ ចំនួន ២៥.០០០ក្បាល ការបោះពុម្ពផ្សាយលេខ ៧-២០០៥ ខែតុលា ឆ្នាំ ២០០៥